00212081

C33/I/6

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៩)**

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / AUG / 2008
ម៉ោង (Time/Heure): 15 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**កាលបរិច្ឆេទ:** ១៣ សីហា ២០០៨

---

**សាធារណៈ**

**សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡូ ជុនធី
នី ចាន់ឌី
កង់ ពិសី
Silke Studzinsky
យុង ផានិត

**សហមេធាវីការពារក្តី**

សុន អារុណ
Michiel PESTMAN
Victor KOPPE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 08 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក")** បានទទួលលិខិតរបស់ Sadie Blanchard និង Annie Gell ជាមន្ត្រីជំនួយផ្នែកច្បាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM) ចុះថ្ងៃទី ២៥ កក្កដា ២០០៨ ដែលបានស្នើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីពី "ការដាក់ជនជាប់ឃុំបណ្តោះអាសន្នឱ្យនៅដាច់ដោយឡែកពីគ្នា តាមករណីជាក់ស្តែង" នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន។

២. វិធាន ៣៣(១)នៃវិធានផ្ទៃក្នុង ចែងថា:

> នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសអោយបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចអញ្ជើញ ឬផ្តល់ឱកាសអោយអង្គការ ឬបុគ្គលណាមួយប្រគល់ជូននូវសារណាជាលាយល័ក្ខអក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បានក្នុងនាមជាអ្នកឯកទេសអមតុលាការ។ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ដែលពាក់ព័ន្ធត្រូវកំណត់ពេលវេលាអោយដាក់សារណានេះ ប្រសិនបើត្រូវធ្វើ។

៣. អង្គបុរេជំនុំជម្រះយល់ឃើញថា តាមរយៈសារណារបស់ភាគីនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងក្រោយពីបានពិចារណាលើការពិនិត្យបញ្ហាដូចគ្នានេះនៅក្នុងករណីមុន អង្គជំនុំជម្រះមានព័ត៌មានគ្រប់គ្រាន់ក្នុងការសម្រេចបណ្តឹងឧទ្ធរណ៍នេះ។ នៅក្នុងកាលៈទេសៈទាំងនេះ យើងមិនចង់ឱ្យមានហានិភ័យចំពោះការពន្យារពេលនីតិវិធី ដោយសារការទទួលយកសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី និងសេចក្តីសន្និដ្ឋានតបរបស់ភាគី។

៤. អង្គបុរេជំនុំជម្រះស្វាគមន៍ការចាប់អារម្មណ៍ដែលបានលើកឡើងដោយ Sadie Blanchard និង Annie Gell នៅក្នុងកិច្ចដំណើរការនីតិវិធីមួយនេះ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ខ្លួនមិនមានបំណងផ្តល់ការអនុញ្ញាតចំពោះសំណើសុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនៅក្នុងករណីនេះឡើយ។

៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណើសុំការអនុញ្ញតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីពីការបកប្រែឯកសារ ទៅជាភាសាឱ្យជនត្រូវចោទ និងមេធាវីរបស់ពួកគេយល់នោះ ដែលមានលើកឡើងផងដែរនៅក្នុងលិខិតចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ នឹងលើកឡើងដាច់ដោយឡែកពីគ្នា ដោយសារវាពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍ខុសៗគ្នា។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច:**

បដិសេធ សំណើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ដែលប្តឹងប្រឆាំងនឹងដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន។ ៕

ភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

**ប្រាក់ គឹមសាន**